ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...១៨៤១៤...អពដ

L202404240281TD4109

ថ្ងៃ ចន្ទ ១៣ កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០២៤

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនលោក-លោកស្រី ម្ចាស់សហគ្រាសធុនមីក្រូ តូច និងមធ្យម ទាំងអស់ ជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ដើម្បីផ្តល់នូវការធានា និងការលើកទឹកចិត្តដល់សហគ្រាសដែលប្រកបអាជីវកម្មមានលក្ខណៈមីក្រូ តូច និងមធ្យម ហើយស្ថិតនៅក្រៅប្រព័ន្ធចូលរួមក្នុងការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត និងរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចតទៅ៖

### I. វិសាលភាព

ការលើកទឹកចិត្តផ្នែកពន្ធដារនេះ ត្រូវបានផ្តល់ជូនចំពោះសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ដើម្បីប្រកបអាជីវកម្មក្នុងវិស័យអាទិភាពណាមួយរួមមាន៖ ១). លក់ដុំ លក់រាយ និងជួសជុល ២). សេវាកម្មស្នាក់នៅនិងអាហារ ៣). សិប្បកម្ម និង៤). សហគមន៍កសិកម្ម ដែលបានកំណត់តាមលេខកូដសកម្មភាពអាជីវកម្មលម្អិតតាមវិស័យរៀងនីមួយៗ ដូចមានក្នុងតារាងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

### II. ការលើកទឹកចិត្តផ្នែកពន្ធដារ

ការលើកទឹកចិត្តផ្នែកពន្ធដារ មានដូចខាងក្រោម៖

១- ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ ២០២៣-២០២៨ សម្រាប់សហគ្រាសធុនមីក្រូ បានការលើកលែងកម្រៃសេវាចុះបញ្ជីពន្ធដារ កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន និងកម្រៃសេវាបោះពុម្ពបណ្ណសម្គាល់ការចុះបញ្ជី។

២- ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ ២០២៣-២០២៨ សម្រាប់សហគ្រាសធុនតូច ទទួលបានការលើកលែងដូចតទៅ៖

- ពិន័យទោសទណ្ឌនិងបំណុលពន្ធ រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ពាក់ព័ន្ធផ្ទាល់នឹងអាជីវកម្មរបស់សហគ្រាស ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត
- កម្រៃសេវាចុះបញ្ជីពន្ធដារ កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន និងកម្រៃសេវាបោះពុម្ពបណ្ណសម្គាល់ការចុះបញ្ជី
- ពន្ធប៉ាតង់ នៅពេលចុះបញ្ជីពន្ធដារ



អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

- ពន្ធប៉ាតង់ សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារបានសម្រេច ក្នុងឆ្នាំ២០២៤ ឬឆ្នាំ២០២៥
- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារ ដោយគិតចាប់ពីឆ្នាំទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារ និងឆ្នាំជាប់ពន្ធបន្ទាប់។

៣-ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ ២០២៤-២០២៥ សម្រាប់សហគ្រាសធុនមធ្យម ទទួលបានការលើកលែងដូចតទៅ៖

- ពិន័យទោសទណ្ឌនិងបំណុលពន្ធ រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ ពាក់ព័ន្ធផ្ទាល់នឹងអាជីវកម្មរបស់សហគ្រាស ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុន ការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត
- ពន្ធប៉ាតង់ នៅពេលចុះបញ្ជីពន្ធដារ
- ពន្ធប៉ាតង់ សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារបានសម្រេច ក្នុងឆ្នាំ២០២៤ ឬឆ្នាំ២០២៥
- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារ ដោយគិតចាប់ពីឆ្នាំទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារ និងឆ្នាំជាប់ពន្ធបន្ទាប់។

## III. ការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត

ការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត អាចធ្វើឡើងតាមរយៈការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ដែលមានតំណភ្ជាប់ https://www.registrationservices.gov.kh ឬចុះបញ្ជីដោយផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារ ដោយបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារឬបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ ១០១) ស្របតាមប្រកាសស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ជាធរមាន។

ដោយឡែក ការចុះបញ្ជីពន្ធដារមិនត្រូវបានចាត់ទុកជាការចុះបញ្ជីដោយស្ម័គ្រចិត្តទេ ក្នុងករណីការចុះបញ្ជីត្រូវបានធ្វើឡើងជាឯកតោភាគីដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីសហគ្រាសធុនតូចនិងមធ្យម មិនបានមកចុះបញ្ជីតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយទទួលបានលិខិតអញ្ជើញលើកទី២។

## IV. លក្ខខណ្ឌទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ

សហគ្រាសធុនមីក្រូ តូច និងមធ្យម ទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ក្នុងករណីបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- ស្ថិតនៅក្នុងវិស័យអាទិភាព នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចមានចែងក្នុងចំណុច I នៃសេចក្តីណែនាំនេះ និង
- ចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ដូចមានចែងក្នុងចំណុច III នៃសេចក្តីណែនាំនេះ។

សហគ្រាសទទួលបានលិខិតបញ្ជាក់ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ ស្របតាមយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ និងឯកសារផ្លូវការសម្រាប់ការចុះបញ្ជីពន្ធដារ ជាទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជីអាជីវកម្ម ដែលមានតំណភ្ជាប់ https://www.registrationservices.gov.kh ឬអាចស្នើសុំបោះពុម្ពដោយផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារ៖ ១).ការិយាល័យចុះបញ្ជីពន្ធដារ នៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ឬ ២).សាខាពន្ធដារខេត្ត-ខណ្ឌ តាមទីតាំងភូមិសាស្ត្រដែលសហគ្រាសស្ថិតនៅ។

L202404240281TD4109

រដ្ឋបាលសារពើពន្ធអាចចុះដល់ទីតាំងអ្នកជាប់ពន្ធ ដើម្បីប្រគល់ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ ពិនិត្យផ្ទៀងផ្ទាត់ចំណុចនិយាមកាទីតាំង ថតរូបទីតាំង កត់ត្រាទិន្នន័យទីតាំងផ្សេងៗ ឬធ្វើការណែនាំអំពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

## V. កាតព្វកិច្ចសារពើពន្ធ

សហគ្រាសដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារនេះ ត្រូវបំពេញកាតព្វកិច្ចសារពើពន្ធដូចខាងក្រោម៖

១- សហគ្រាសធុនមីក្រូ ត្រូវជូនដំណឹងមករដ្ឋបាលសារពើពន្ធអំពី៖

- ផលរបរប្រចាំឆ្នាំ តាមទម្រង់កំណត់ដោយរដ្ឋបាលសារពើពន្ធ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់
- ការផ្លាស់ប្តូរព័ត៌មានផ្សេងៗ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម លេខទូរស័ព្ទ និងសារអេឡិចត្រូនិក។

២- សហគ្រាសធុនតូចនិងមធ្យម ត្រូវ៖

- ជូនដំណឹងមករដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរនិងការផ្លាស់ប្តូរម្ចាស់ភាគហ៊ុន សមាសភាពអ្នកគ្រប់គ្រងសហគ្រាសឬសាខា ការបញ្ឈប់អាជីវកម្ម អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ព័ត៌មានគណនីធនាគារ ព័ត៌មានទំនាក់ទំនង លេខទូរស័ព្ទ និងសារអេឡិចត្រូនិក
- កាន់បញ្ជិកាគណនេយ្យ និងដាក់លិខិតប្រកាសសារពើពន្ធទៅតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវបានលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា
- ដាក់លិខិតប្រកាសនិងបង់ពន្ធអាករដទៃទៀតប្រចាំខែ និងប្រចាំឆ្នាំ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាធរមាន។

*ដើម្បីស្វែងយល់បន្ថែមអំពីការអនុវត្តនេះ អ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទាំងអស់អាចអញ្ជើញមកសាកសួរព័ត៌មានដោយផ្ទាល់នៅបញ្ជរផ្តល់សេវាអ្នកជាប់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬទូរស័ព្ទមកមជ្ឈមណ្ឌលពិគ្រោះយោបល់ (Call Center 1277) ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។*

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រី ដែលជាម្ចាស់សហគ្រាសធុនមីក្រូ តូច និងមធ្យម ទាំងអស់នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យបានត្រឹមត្រូវនិងទទួលបានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

L202404240281TD4109

# ឧបសម្ព័ន្ធ

# នៃសេចក្តីណែនាំលេខ១៥៤១២ សហវ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤ ស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សហគ្រាសធុនមីក្រូ តូច និងមធ្យម ទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចំពោះសកម្មភាពអាជីវកម្ម ដូចខាងក្រោម៖

## ១. លក់ដុំ លក់រាយ និងជួសជុល

| | | |
|---|---|---|
| ១ | ៤៥៣០០ | ទិញលក់គ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំរថយន្ត រាប់បញ្ចូល ការលក់ដុំនិងលក់រាយ កៅស៊ូកង់ ពោះវៀនកង់ ក្បាលប៊ូស៊ី អាគុយ ឧបករណ៍ភ្លើង និង គ្រឿងបន្លាស់អគ្គិសនី |
| ២ | ៤៥៤០២ | ទិញលក់គ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំទោចក្រយានយន្ត |
| ៣ | ៤៥៤០៣ | ជួសជុលនិងថែទាំទោចក្រយានយន្ត |
| ៤ | ៤៥២០១ | ជួសជុលនិងតុបតែងរថយន្ត |
| ៥ | ៤៥២០២ | លាបថ្នាំ និងបាញ់ថ្នាំ |
| ៦ | ៤៥២០៣ | លាង ប៉ូលារថយន្ត |
| ៧ | ៤៥២០៤ | ជួសជុលកៅអីរថយន្ត |
| ៨ | ៤៥២០៥ | ជួសជុលកង់ និងពោះវៀនកង់ការផ្លាស់ប្តូរ ឬការប៉ះពោះវៀនធ្លាយ |
| ៩ | ៤៥២០៦ | ការដំឡើងគ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំផ្សេងៗដែលមិនបានដំឡើងពីរោងចក្រ |
| ១០ | ៤៧១១១ | គ្រឿងឧបភោគបរិភោគជាលក្ខណៈហាងលក់គ្រឿងទេស |
| ១១ | ៤៧១១៣ | គ្រឿងឧបភោគបរិភោគជាលក្ខណៈផ្សារទំនើបខ្នាតតូច រាប់បញ្ចូល ភាគច្រើនលក់ទំនិញមានស្លាកយីហោ ជាទូទៅ មាននៅក្នុងទីក្រុងធំៗពេលខ្លះបើក ២៤ម៉ោង (Minimarts) |
| ១២ | ៤៧១៩២ | ហាងចម្រុះផ្សេងទៀត រាប់បញ្ចូល ជាហាងធម្មតា ដែលមិនមានលក់អាហារភេសជ្ជៈ និងផលិតផលថ្នាំជក់ភាគច្រើនទេ |
| ១៣ | ៤៧២១១ | ទិញលក់អង្ករ ម្សៅ គ្រាប់ធញ្ញជាតិ និងស្ករ |
| ១៤ | ៤៧២១២ | ទិញលក់បន្លែ និងផ្លែឈើស្រស់ ឬរក្សាទុកក្រៀម |
| ១៥ | ៤៧២១៣ | ទិញលក់សាច់ និងផលិតផលសាច់ (រួមទាំងបក្សី) |
| ១៦ | ៤៧២១៤ | ទិញលក់ត្រី គ្រឿងសមុទ្រ និងផលិតផលប្រហាក់ប្រហែល |
| ១៧ | ៤៧២១៥ | ទិញលក់ ផលិតផលនំប៉័ង |
| ១៨ | ៤៧២១៦ | ទិញលក់ផលិតផលស្ករគ្រាប់ និងនំ |
| ១៩ | ៤៧២១៧ | ទិញលក់មី ស្បែក និងផលិតផលអាហារផ្សេងទៀតធ្វើពីម្សៅមី និងសណ្តែកសៀង |
| ២០ | ៤៧២១៨ | ទិញលក់ផលិតផលដែលធ្វើពីទឹកដោះគោ |
| ២១ | ៤៧២១៩ | ទិញលក់នូវផលិតផលអាហារផ្សេងៗ |

L202404240281TD4109

| | | |
|---|---|---|
| ២២ | ៤៧២២២ | ទិញលក់តែ កាហ្វេ និងភេសជ្ជៈផ្សេងទៀត |
| ២៣ | ៤៧២២៣ | ទិញលក់ភេសជ្ជៈ ទឹកក្រូចជប និងទឹកកក |
| ២៤ | ៤៧៤១១ | ទិញលក់កុំព្យូទ័រ និងឧបករណ៍បន្ទាប់បន្សំ |
| ២៥ | ៤៧៤១២ | ទិញលក់ឧបករណ៍លេងហ្គេម |
| ២៦ | ៤៧៤១៣ | ទិញលក់កម្មវិធីសម្រាប់ប្រើទូទៅ រួមមានវីដេអូហ្គេម |
| ២៧ | ៤៧៤១៤ | ទិញលក់ទូរស័ព្ទដៃ និងឧបករណ៍ទូរគមនាគមន៍ផ្សេងៗ |
| ២៨ | ៤៧៤២១ | ទិញលក់គ្រឿងវិទ្យុ និងទូរទស្សន៍ |
| ២៩ | ៤៧៤២២ | ទិញលក់ម៉ាស៊ីនចាក់ ម៉ាស៊ីនថតស៊ីឌី ឌីវីឌី ឧបករណ៍បំពងសំឡេងនិងឧបករណ៍សំឡេង |
| ៣០ | ៤៧៥១០ | ទិញលក់ផលិតផលវាយនភណ្ឌ ក្រណាត់ និងអំបោះសម្រាប់ចាក់ រាប់បញ្ចូល ម្ជុលដេរ អំបោះដេរ។ល។ |
| ៣១ | ៤៧៥២០ | ការលក់រាយសម្ភារៈផ្នែករឹង ថ្នាំលាប និងផ្ទាំងកញ្ចក់ |
| ៣២ | ៤៧៥៣១ | ទិញលក់កម្រាលព្រំ និងក្រណាត់ជូតជើង |
| ៣៣ | ៤៧៥៣២ | ទិញលក់វាំងនន និងវាំងននសំណាញ់ |
| ៣៤ | ៤៧៥៣៣ | ទិញលក់ក្រដាសបិទជញ្ជាំង និងកម្រាលផ្សេងៗ |
| ៣៥ | ៤៧៥៩១ | ទិញលក់គ្រឿងសង្ហារិមនៅក្នុងផ្ទះ រាប់បញ្ចូល គ្រឿងសង្ហារិមធ្វើពីផ្តៅ និងឈើ |
| ៣៦ | ៤៧៥៩២ | ទិញលក់គ្រឿងបំភ្លឺ |
| ៣៧ | ៤៧៥៩៣ | ទិញលក់សម្ភារៈប្រើក្នុងផ្ទះបាយ កាំបិត ចង្ក្រាន កែវ ចាន និងឆ្នាំង |
| ៣៨ | ៤៧៥៩៤ | ទិញលក់ឧបករណ៍ប្រើក្នុងផ្ទះ |
| ៣៩ | ៤៧៥៩៥ | ទិញលក់ឧបករណ៍តន្ត្រី |
| ៤០ | ៤៧៥៩៦ | ឧបករណ៍ប្រព័ន្ធសុវត្ថិភាព៖ គ្រឿងចាក់សោសុវត្ថិភាព បន្ទប់រក្សាសុវត្ថិភាពក្រោមដី |
| ៤១ | ៤៧៥៩៩ | ទិញលក់ឧបករណ៍និងសម្ភារៈប្រើក្នុងគ្រួសារដែលមិនបានរាប់ចូល |
| ៤២ | ៤៧៦១១ | ទិញលក់សម្ភារៈនិងបរិក្ខារការិយាល័យ រាប់បញ្ចូល Stationery |
| ៤៣ | ៤៧៦១២ | ទិញលក់សៀវភៅ កាសែត |
| ៤៤ | ៤៧៦២០ | ទិញលក់តន្ត្រី និងវីដេអូ ដែលថតដាក់ឌីស ស៊ីឌី និងឌីវីឌី |
| ៤៥ | ៤៧៦៣១ | ទិញលក់ទំនិញ និងឧបករណ៍កីឡា រួមមានប្រដាប់ស្ទូចត្រី |
| ៤៦ | ៤៧៦៣២ | ទិញលក់ទំនិញសម្រាប់បោះជំរំ |
| ៤៧ | ៤៧៦៣៣ | ទិញលក់ទូក និងឧបករណ៍ពាក់ព័ន្ធ |
| ៤៨ | ៤៧៦៣៤ | ទិញលក់កង់ និងគ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំ |
| ៤៩ | ៤៧៦៤០ | ទិញលក់ល្បែងនិងប្រដាប់ក្មេងលេង ធ្វើពីគ្រប់សារធាតុ |
| ៥០ | ៤៧៧១១ | ទិញលក់សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ |
| ៥១ | ៤៧៧១២ | ទិញលក់ផលិតផលពាក់នឹងជើង |
| ៥២ | ៤៧៧២២ | ហាងមានឯកទេសលក់ជុំនិងរាយទឹកអប់ និងគ្រឿងសម្អាង |
| ៥៣ | ៤៧៧៣១ | ទិញលក់ឧបករណ៍ថតរូប និងផលិតផលទាក់ទង |

| | | |
|---|---|---|
| ៥៤ | ៤៧៧៣២ | ទិញលក់នាឡិកាដៃ នាឡិកាព្យួរជញ្ជាំង និងគ្រឿងអលង្ការ |
| ៥៥ | ៤៧៧៣៣ | ទិញលក់ផ្កា រុក្ខជាតិ គ្រាប់ពូជ |
| ៥៦ | ៤៧៧៣៤ | ទិញលក់វត្ថុអនុស្សាវរីយ ផលិតផលសិប្បកម្ម សម្ភារៈសាសនា |
| ៥៧ | ៤៧៧៣៥ | ទិញលក់ប្រេងសម្រាប់ប្រើក្នុងផ្ទះ ហ្គាសកំប៉ុង ធ្យូង អុស |
| ៥៨ | ៤៧៧៣៦ | ទិញលក់វ៉ែនតា និងផលិតផលអុបទិចផ្សេងៗទៀត |
| ៥៩ | ៤៧៧៣៧ | ទិញលក់ត្រី សត្វចិញ្ចឹម និងចំណីសម្រាប់សត្វចិញ្ចឹម |
| ៦០ | ៤៧៧៤១ | ទិញលក់សៀវភៅជជុះ |
| ៦១ | ៤៧៧៤២ | ទិញលក់ផលិតផលអគ្គិសនី និងអេឡិចត្រូនិកជជុះ |
| ៦២ | ៤៧៧៤៣ | ទិញលក់វត្ថុបុរាណ |
| ៦៣ | ៤៧៧៤៩ | ទិញលក់ផលិតផលជជុះផ្សេងៗ រាប់បញ្ចូល តែមប្រៃសណីយ៍ និងកាក់ |
| ៦៤ | ៤៧៨១០ | ការលក់រាយអាហារ ភេសជ្ជៈ ថ្នាំជក់នៅតាមតូប និងទីផ្សារ |
| ៦៥ | ៤៧៨១១ | ទិញលក់គ្រឿងម៉ាស៊ីនឧបករណ៍ និងបរិក្ខារផ្គត់ផ្គង់កសិកម្ម |
| ៦៦ | ៤៧៨១២ | ទិញលក់ជ័រកៅស៊ូ |
| ៦៧ | ៤៧៨១៣ | ទិញលក់ប្រេងដូង |
| ៦៨ | ៤៧៨១៤ | ទិញលក់ដំឡូងមី |
| ៦៩ | ៤៧៨១៥ | ទិញលក់ពោតឧស្សាហកម្ម |
| ៧០ | ៤៧៨១៦ | ទិញលក់គ្រាប់ស្វាយចន្ទី |
| ៧១ | ៤៧៨១៩ | ទិញលក់វត្ថុធាតុដើមកសិកម្មផ្សេងទៀត |
| ៧២ | ៤៧៨៣១ | ទិញលក់ឈើហុប ឈើអារ ក្ដារបន្ទះ បន្ទះក្ដារស្ដើងនិងផលិតផលពាក់ព័ន្ធ |
| ៧៣ | ៤៧៨៣២ | ទិញលក់ថ្នាំលាប និងថ្នាំលាបឈើឱ្យរលោង |
| ៧៤ | ៤៧៨៣៣ | ទិញលក់ឧបករណ៍ និងសម្ភារៈសំណង់ រាប់បញ្ចូលៈ ក).សម្ភារៈសំណង់ ដូចជាខ្សាច់ ថ្ម ក្រាល ស៊ីម៉ង់ត៍ ថ្ម បាយអ ខ).ក្រដាសបិទជញ្ជាំង កញ្ចក់រាប និងកម្រាល |
| ៧៥ | ៤៧៨៣៤ | ទិញលក់គ្រឿងសម្រាប់បន្ថែមភ្ជាប់លើអគារ ឬសង្ហារិម |
| ៧៦ | ៤៧៨៣៥ | ទិញលក់ម៉ាស៊ីនទឹកក្ដៅ និងឧបករណ៍អនាម័យ និងម៉ាស៊ីនកម្ដៅទឹក |
| ៧៧ | ៤៧៨៤១ | ទិញលក់សារធាតុគីមីសម្រាប់ឧស្សាហកម្ម រាប់បញ្ចូល ល័ក្ត ទឹកថ្នាំបោះពុម្ព ប្រេងចាំបាច់ ឧស្ម័នឧស្សាហកម្ម កាវគីមី សារធាតុធ្វើពណ៌ ជ័រទឹកសំយោគ មេតាណុល ជ័រចំហេះ មេក្លិន មេរសជាតិ សូដា អំបិលឧស្សាហកម្ម អាស៊ីត និងស៊ុលផួរ ម្សៅដំឡូងមិនមែនផលិតពីវត្ថុធាតុដើម។ល។ |
| ៧៨ | ៤៧៨៤២ | ទិញលក់ជី និងផលិតផលគីមីកសិកម្ម |
| ៧៩ | ៤៧៨៤៣ | ទិញលក់សម្ភារៈធ្វើពីប្លាស្ទិកមិនទាន់កែច្នៃ |
| ៨០ | ៤៧៨៤៤ | ទិញលក់សរសៃអំបោះវាយនភណ្ឌ។ល។ |
| ៨១ | ៤៧៨៤៥ | ទិញលក់ក្រដាសក្នុងចំនួនច្រើន និងសម្ភារៈវេចខ្ចប់ |

L202404240281TD4109

| | | |
|---|---|---|
| ៨២ | ៤៧៨៥១ | ទិញលក់កាកសំណល់ និងកម្ទេចកម្ទី រាប់បញ្ចូល ប្រមូលទុក ញែក ស្តុក និងចែកចាយ ប៉ុន្តែមិនមានដំណើរការបំប្លែងពិតប្រាកដ |
| ៨៣ | ៤៧៨៥២ | ការរុះកម្ទេចរថយន្ត កុំព្យូទ័រ ទូរទស្សន៍ និងឧបករណ៍ផ្សេងៗទៀតដើម្បីយក និងលក់បន្តនូវផ្នែកណាមួយដែលប្រើប្រាស់បាន |
| ៨៤ | ៤៧៨៥៩ | ទិញលក់កម្ទេចកម្ទី កាកសំណល់ និងផលិតផលផ្សេងៗ |
| ៨៥ | ៤៧៨៩១ | ការលក់រាយកម្រាលព្រំ និងកម្រាលជើងនៅតាមតូប ឬទីផ្សារ |
| ៨៦ | ៤៧៨៩២ | ការលក់រាយសៀវភៅនៅតាមតូប ឬទីផ្សារ |
| ៨៧ | ៤៧៨៩៣ | ការលក់រាយហ្គេម និងប្រដាប់ក្មេងលេងនៅតាមតូបឬទីផ្សារ |
| ៨៨ | ៤៧៨៩៤ | ការលក់រាយគ្រឿងបរិក្ខារប្រើក្នុងផ្ទះ និងគ្រឿងអេឡិចត្រូនិកសម្រាប់អ្នកប្រើប្រាស់នៅតាមតូប ឬទីផ្សារ |
| ៨៩ | ៤៧៨៩៥ | ការលក់រាយតន្ត្រី និងវីដេអូនៅតាមតូប ឬទីផ្សារ |
| ៩០ | ៤៧៩១០ | បញ្ជាទិញតាមអ៊ីនធឺណិតឬទូរស័ព្ទ រាប់បញ្ចូល Amazon, Alibaba |
| ៩១ | ៣៣១១០ | ការជួសជុលផលិតផលលោហធាតុកែច្នៃ |
| ៩២ | ៣៣១២០ | ការជួសជុលគ្រឿងម៉ាស៊ីន |
| ៩៣ | ៣៣១៣០ | ការជួសជុលឧបករណ៍អេឡិចត្រូនិកនិងអុបទិក |
| ៩៤ | ៣៣១៤០ | ការជួសជុលបរិក្ខារអគ្គិសនី |
| ៩៥ | ៣៣១៥០ | ការជួសជុលបរិក្ខារដឹកជញ្ជូន |
| ៩៦ | ៣៣១៩០ | ការជួសជុលឧបករណ៍ដទៃផ្សេងទៀត |

## ២. សេវាកម្មស្នាក់នៅនិងអាហារ

| | | |
|---|---|---|
| ១ | ៥៥១០៤ | ផ្ទះសំណាក់ ផ្ទះជួល |
| ២ | ៥៥១០៥ | ផ្ទះស្នាក់អាស្រ័យ |
| ៣ | ៥៥២០០ | កន្លែងបោះជំរំ ចំណតសម្រាប់យានយន្តទេសចរណ៍ |
| ៤ | ៥៥៩០១ | កន្លែងស្នាក់នៅរបស់និស្សិត និងអន្តេវាសិកដ្ឋានសម្រាប់សិស្ស |
| ៥ | ៥៥៩០៩ | អន្តេវាសិកដ្ឋានផ្សេងៗទៀត រាប់បញ្ចូលផ្ទះសំណាក់ បន្ទប់ និងផ្ទះសម្រាប់កម្មករ |
| ៦ | ៥៦១០១ | ភោជនីយដ្ឋាន |
| ៧ | ៥៦១០២ | កន្លែងលក់អាហាររហ័ស ហាងលក់ចំណីហូបចុកសម្រាប់ហូបលេង |
| ៨ | ៥៦១០៣ | ហាងលក់ការ៉េម និងការដើរលក់តាមរថយន្ត |
| ៩ | ៥៦១០៤ | រទេះចល័តលក់អាហារ |
| ១០ | ៥៦១០៥ | ស្តង់លក់ម្ហូបអាហារអ្នកដើរលក់ និងការរៀបចំលក់ម្ហូបអាហារនិងភេសជ្ជៈក្នុងផ្សារ |
| ១១ | ៥៦២១០ | ការផ្គត់ផ្គង់ម្ហូបអាហារដល់កម្មវិធី |
| ១២ | ៥៦២៩០ | សកម្មភាពផ្តល់សេវាកម្មម្ហូបអាហារដទៃទៀតរាប់បញ្ចូល៖ ក).ប្រតិបត្តិការហាងអាហារ និងហាងកាហ្វេ (ដូចជាសម្រាប់រោងចក្រ ការិយាល័យ មន្ទីរពេទ្យ ឬសាលារៀន) មានលក្ខណៈ |

L202404240281TD4109

| | | |
|---|---|---|
| | | សម្បទាន ខ).អ្នកម៉ៅការសេវាកម្មម្ហូបអាហារ សម្រាប់ក្រុមហ៊ុនដឹកជញ្ជូន គ).ប្រតិបត្តិការកន្លែងលក់អាហារនៅទីលានហាត់កីឡាឬសកម្មភាពប្រហាក់ ប្រហែលដែលមានលក្ខណៈជាសម្បទាន |
| ១៣ | ៥៦៣០១ | តៀមស្រា វង្គសាល ឌីស្កូ បៀរហ្គាដិន និងហាងខារ៉ាអូខេ |
| ១៤ | ៥៦៣០២ | ហាងតែ និងកាហ្វេ |
| ១៥ | ៥៦៣០៣ | តៀមលក់ភេសជ្ជៈ |
| ១៦ | ៥៦៣០៤ | រទេះលក់ភេសជ្ជៈចល័ត |
| ១៧ | ៥៦៣០៩ | កន្លែងផ្តល់សេវាកម្មភេសជ្ជៈ និងអាហារផ្សេងៗដែលមិនរាប់បញ្ចូល |

## ៣. សិប្បកម្ម

| | | |
|---|---|---|
| ១ | ១០១១១ | សត្តឃាត និងការវេចខ្ចប់សាច់គោ និងសាច់ក្របី |
| ២ | ១០១១២ | សត្តឃាត និងការវេចខ្ចប់សាច់ជ្រូក |
| ៣ | ១០១១៩ | សត្តឃាត និងការវេចខ្ចប់សាច់ដែលពុំបានរាប់បញ្ចូល |
| ៤ | ១០១២១ | សត្តឃាត និងការវេចខ្ចប់សាច់មាន់ |
| ៥ | ១០១២២ | សត្តឃាត និងការវេចខ្ចប់សាច់ទា |
| ៦ | ១០១២៣ | សត្តឃាត និងការវេចខ្ចប់សាច់ក្រួច |
| ៧ | ១០១២៩ | សត្តឃាត និងការវេចខ្ចប់សាច់បក្សាបក្សីដែលពុំបានរាប់បញ្ចូល |
| ៨ | ១០១៣១ | ផលិតកម្មសាច់បង្គក |
| ៩ | ១០១៣២ | ផលិតកម្មសម្ងួតប្រឡាក់ឬឆ្អើរសាច់ |
| ១០ | ១០១៣៣ | ផលិតកម្មសាច់អាំង |
| ១១ | ១០១៣៤ | ផលិតកម្មផ្អកសាច់ |
| ១២ | ១០១៣៥ | ផលិតកម្មសាច់ក្រក |
| ១៣ | ១០១៣៦ | ផលិតកម្មប្រហិត |
| ១៤ | ១០១៣៩ | ការកែច្នៃនិងការរក្សាសាច់និងផលិតផលសាច់សត្វបសុបក្សី ដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៥ | ១០២១១ | ការកែច្នៃនិងការថែរក្សាទុកសាច់ត្រីទុកដោយក្លាសេ ក្លាសេក្នុងកម្រិតខ្ពស់ |
| ១៦ | ១០២១២ | ផលិតកម្មសម្ងួតប្រឡាក់ឬឆ្អើរត្រី |
| ១៧ | ១០២១៣ | ផលិតកម្មប្រហុកផ្អក |
| ១៨ | ១០២១៤ | ផលិតកម្មប្រហិតត្រី |
| ១៩ | ១០២១៩ | ការកែច្នៃនិងការរក្សាទុកសាច់ត្រីនិងផលិតផលសាច់ត្រី សាច់ត្រីស្រស់ បង្កកឬក្លាសេ ដែលពុំបានរាប់បញ្ចូល |
| ២០ | ១០២២០ | ផលិតផលត្រីខកំប៉ុង |
| ២១ | ១០២៣០ | ការកែច្នៃ និងការថែរក្សា សន្តវន្តសត្វ (បង្កង ក្តាម) និងសិប្បីសត្វ (ខ្យង គ្រំ) |
| ២២ | ១០២៤០ | ផលិតកម្ម សន្តវន្តសត្វ និងសិប្បីសត្វកំប៉ុង |

L202404240281TD4109

| | | |
|---|---|---|
| ២៣ | ១០២៥០ | ផលិតកម្ម និងការកែច្នៃសារ៉ាយសមុទ្រ |
| ២៤ | ១០២៩១ | ការកែច្នៃផលិតផលគ្រឿងសមុទ្រចំហុយ |
| ២៥ | ១០២៩២ | ផលិតកម្មត្រីសមុទ្រក្រៀម បង្គា មឹក |
| ២៦ | ១០២៩៣ | ផលិតកម្មកាពិ |
| ២៧ | ១០២៩៩ | ការកែច្នៃ និងរក្សាទុកផលិតផលត្រី គ្រឿងសមុទ្រដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ២៨ | ១០៣១១ | ការកែច្នៃ និងការរក្សាទុកផ្លែឈើ |
| ២៩ | ១០៣១២ | ការកែច្នៃ និងការរក្សាទុកបន្លែ |
| ៣០ | ១០៣១៣ | ការកែច្នៃ និងការរក្សាទុកគ្រាប់ផ្លែឈើក្រៀម |
| ៣១ | ១០៣១៩ | ការកែច្នៃ និងការរក្សាទុកផ្លែឈើ និងបន្លែដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៣២ | ១០៣២១ | ផលិតកម្មបន្លែច្រកកំប៉ុង |
| ៣៣ | ១០៣២២ | ផលិតកម្មផ្លែឈើច្រកកំប៉ុង |
| ៣៤ | ១០៣៣១ | ផលិតកម្មទឹកផ្លែឈើ |
| ៣៥ | ១០៣៣២ | ផលិតកម្មទឹកបន្លែ |
| ៣៦ | ១០៣៩១ | ផលិតកម្មផលិតផលសណ្ដែកសៀងផ្អាប់ |
| ៣៧ | ១០៣៩២ | ផលិតកម្មតៅហ៊ូ |
| ៣៨ | ១០៣៩៩ | ផលិតកម្មផលិតផលផ្លែឈើឬបន្លែដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៣៩ | ១០៤១១ | កម្មន្តសាលប្រេងដែលបានពីបន្លែ |
| ៤០ | ១០៤២០ | កម្មន្តសាលប្រេងដូង នំធ្វើពីសាច់ដូងស្ងួត អាហារនិងនំគ្រាប់តូចៗធ្វើពីសាច់ដូង |
| ៤១ | ១០៤៣០ | កម្មន្តសាលប្រេងពីដូងប្រេង |
| ៤២ | ១០៤៤០ | កម្មន្តសាលប្រេងពោត |
| ៤៣ | ១០៤៥០ | កម្មន្តសាលប្រេង និងខ្លាញ់ដែលបានពីសត្វ |
| ៤៤ | ១០៤៩០ | កម្មន្តសាលប្រេងនិងខ្លាញ់ដែលបានពីបន្លែ និងសត្វដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៤៥ | ១០៥១០ | ការកែច្នៃទឹកដោះគោស្រស់ និងកម្មន្តសាលនៃក្រែម |
| ៤៦ | ១០៥២០ | កម្មន្តសាលម្សៅទឹកដោះគោនិងទឹកដោះគោខាប់ឬទឹកដោះគោបង្អួត (បំពេញផ្សំបញ្ចូលគ្នាឬលាយសាឡើងវិញ) |
| ៤៧ | ១០៥៣១ | កម្មន្តសាលការ៉េម |
| ៤៨ | ១០៥៣២ | កម្មន្តសាលការ៉េមប្រអប់ ការ៉េមដើម និងទឹកកករសជាតិដទៃទៀត |
| ៤៩ | ១០៥៣៩ | កម្មន្តសាលការ៉េម ការ៉េមប្រអប់ ទឹកកកអនាម័យ ការ៉េមដើម និងទឹកកករសជាតិដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៥០ | ១០៥៤០ | កម្មន្តសាលផលិតផលពីទឹកដោះគោដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៥១ | ១០៧១១ | កម្មន្តសាលនំប៉័ង |
| ៥២ | ១០៧១២ | កម្មន្តសាលនំខេក ឬនំសម្រន់ |
| ៥៣ | ១០៧១៩ | កម្មន្តសាលនំដុតដទៃទៀតដែលពុំបានរាប់បញ្ចូល |

L202404240281TD4109

| | | |
|---|---|---|
| ៥៤ | ១០៧២១ | កម្មន្តសាលស្ករត្នោត |
| ៥៥ | ១០៧២២ | កម្មន្តសាលស្ករស |
| ៥៦ | ១០៧២៩ | កម្មន្តសាលស្ករដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៥៧ | ១០៧៣០ | កម្មន្តសាលកាកាវសូកូឡា និងស្ករគ្រាប់ |
| ៥៨ | ១០៧៤១ | កម្មន្តសាលគុយទាវ |
| ៥៩ | ១០៧៤២ | កម្មន្តសាលមី |
| ៦០ | ១០៧៤៩ | កម្មន្តសាលមីម៉ាការ៉ូនី មីសរសៃ មីកូស្កូស និងផលិតផលម្សៅមីស្រដៀងគ្នាដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៦១ | ១០៧៥០ | កម្មន្តសាលអាហាររៀបចំរួច និងអាហារវេចខ្ចប់ដាក់ចាន |
| ៦២ | ១០៧៦១ | កម្មន្តសាលកាហ្វេ |
| ៦៣ | ១០៧៦២ | កម្មន្តសាលតែ |
| ៦៤ | ១០៧៦៩ | កម្មន្តសាលកាហ្វេតែ និងឱសថរុក្ខជាតិដែលពុំបានរាប់បញ្ចូល |
| ៦៥ | ១០៧៧១ | កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃ និងគ្រឿងផ្សំផ្សេងៗ |
| ៦៦ | ១០៧៧២ | កម្មន្តសាលទឹកជ្រលក់ |
| ៦៧ | ១០៧៧៣ | កម្មន្តសាលទឹកខ្មេះ |
| ៦៨ | ១០៧៧៩ | កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃទឹកជ្រលក់គ្រឿងផ្សំផ្សេងៗ និងផលិតផលសម្រាប់ធ្វើម្ហូបដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៦៩ | ១០៧៩០ | កម្មន្តសាលផលិតផលចំណីអាហារផ្សេងទៀត ដែលពុំបានរាប់បញ្ចូល |
| ៧០ | ១០៦១១ | ការកែច្នៃគ្រាប់ធញ្ញជាតិដែលបានកិន |
| ៧១ | ១០៦១៩ | កម្មន្តសាល ផលិតផលពីការកិនគ្រាប់ធញ្ញជាតិដទៃទៀត |
| ៧២ | ១០៦២១ | កម្មន្តសាលម្សៅ |
| ៧៣ | ១០៦២២ | កម្មន្តសាលផលិតផលធ្វើពីម្សៅ |
| ៧៤ | ១០៦២៩ | កម្មន្តសាលម្សៅអាមីដុង និងផលិតផលធ្វើពីម្សៅអាមីដុងដទៃទៀត |
| ៧៥ | ១០៦៣១ | ការកិនស្រូវ |
| ៧៦ | ១០៦៣២ | ការកិនពោត |
| ៧៧ | ១០៦៣៩ | កម្មន្តសាលម្សៅពីអង្ករ ពោត |
| ៧៨ | ១០៨០១ | កម្មន្តសាលចំណីបសុបក្សី |
| ៧៩ | ១០៨០២ | កម្មន្តសាលចំណីជ្រូក |
| ៨០ | ១០៨០៣ | កម្មន្តសាលចំណីត្រី |
| ៨១ | ១០៨០៩ | កម្មន្តសាលចំណីសត្វដែលពុំបានរាប់បញ្ចូល |
| ៨២ | ១១០៤១ | កម្មន្តសាលភេសជ្ជៈគ្មានជាតិអាកុល |
| ៨៣ | ១១០៤២ | ការផលិតទឹកសូដា |
| ៨៤ | ១១០៥០ | កម្មន្តសាលទឹកបរិសុទ្ធ ទឹករ៉ែ និងទឹកកក |

L202404240281TD4109

| | | |
|---|---|---|
| ៨៥ | ១៣១១១ | ការរវៃវាយនភណ្ឌកប្បាស |
| ៨៦ | ១៣១១២ | ការរវៃវាយនភណ្ឌសូត្រ |
| ៨៧ | ១៣១១៩ | ការរៀបចំនិងការរវៃសរសៃអំបោះដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៨៨ | ១៣១២១ | តម្បាញកំណាត់កប្បាស |
| ៨៩ | ១៣១២២ | តម្បាញកំណាត់សូត្រ |
| ៩០ | ១៣១២៩ | តម្បាញកំណាត់ដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៩១ | ១៣១៣០ | កម្មន្តសាលផលិតផលវាយនភណ្ឌសម្រេច |
| ៩២ | ១៣៩១១ | កម្មន្តសាលកំណាត់ចាក់ |
| ៩៣ | ១៣៩១៩ | កម្មន្តសាលផ្ទាំងកំណាត់ចាក់ដោយម្ជុលមួយឬច្រើនដែលពុំបានរាប់បញ្ចូល |
| ៩៤ | ១៣៩២០ | កម្មន្តសាលរបស់តុបតែងពីវាយនភណ្ឌលើកលែងសម្លៀកបំពាក់ |
| ៩៥ | ១៣៩៣១ | កម្មន្តសាលកម្រាលព្រំកន្ទេល |
| ៩៦ | ១៣៩៣៩ | កម្មន្តសាលកម្រាលព្រំនិងព្រំតូចៗដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៩៧ | ១៣៩៤១ | កម្មន្តសាលសំណាញ់ |
| ៩៨ | ១៣៩៤៩ | កម្មន្តសាលខ្សែពួរធំ សម្រាប់នាវា ខ្សែពួរខ្សែវេញនិងការចាក់សំណាញ់ដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៩៩ | ១៥១១០ | ការពន្លាត់ស្បែក និងការតុបតែងស្បែក ការតុបតែង និងជ្រលក់ពណ៌រោមសត្វ |
| ១០០ | ១៤១២១ | ការកាត់ដេរសម្លៀកបំពាក់បុរសនិងរ៉ូបស្ត្រីបែបប្រពៃណី |
| ១០១ | ១៤១២៩ | ការកាត់ដេរសម្លៀកបំពាក់បុរស និងរ៉ូបស្ត្រីដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១០២ | ១៤១៣០ | កម្មន្តសាលសម្ភារៈបន្ទាប់បន្សំដែលមានជាតុផ្សំចម្បងធ្វើពីវាយនភណ្ឌ |
| ១០៣ | ១៥១២១ | កម្មន្តសាលវ៉ាលីកាបូបយួរដៃ និងកាបូបស្ពាយក្រោយ |
| ១០៤ | ១៥១២៩ | កម្មន្តសាលវ៉ាលីកាបូបយួរដៃនិងផលិតផលស្រដៀងកែបសេះ និងបង្ហៀរសេះដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១០៥ | ១៥២០១ | កម្មន្តសាលស្បែកជើងធ្វើពីស្បែក |
| ១០៦ | ១៥២០៩ | កម្មន្តសាលស្បែកជើងដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១០៧ | ១៦១០០ | ការអារឈើនិងការឈូសឈើ |
| ១០៨ | ១៦២១០ | កម្មន្តសាលចំនៀរឈើនិងបន្ទះឈើស្តើង |
| ១០៩ | ១៦២២១ | កម្មន្តសាល ទ្វារបង្អួចគម្របនិងគ្រោង |
| ១១០ | ១៦២២២ | កម្មន្តសាលការ៉ូឈើសម្រាប់ធ្វើផ្ទៃក្រាល |
| ១១១ | ១៦២២៩ | កម្មន្តសាលឈើសំណង់ និងឈើតំណ ដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១១២ | ១៦២៣០ | កម្មន្តសាលធុងឈើ |
| ១១៣ | ១៦២៩០ | កម្មន្តសាលផលិតផលឈើផ្សេងទៀត កម្មន្តសាលរបស់របរធ្វើពីឈើស្នោ ចំបើងនិងវត្ថុជាតុក្រង |
| ១១៤ | ១៧០១១ | កម្មន្តសាលកេសក្រដាស |
| ១១៥ | ១៧០១២ | កម្មន្តសាលក្រដាសសរសេរ |

L202404240281TD4109

| | | |
|---|---|---|
| ១១៦ | ១៧០១៩ | កម្មន្តសាលក្រដាស និងផលិតផលក្រដាសដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១១៧ | ១៧០២០ | កម្មន្តសាលក្រដាសទឹករលក ក្រដាសកាតុង និងប្រអប់ធ្វើពីក្រដាសនិងពីក្រដាសកាតុង |
| ១១៨ | ១៧០៩០ | កម្មន្តសាលរបស់របរផ្សេងទៀតធ្វើពីក្រដាស និងពីក្រដាសកាតុង |
| ១១៩ | ១៨១១០ | ការបោះពុម្ព |
| ១២០ | ១៨១២០ | សេវាកម្មទាក់ទងនឹងការបោះពុម្ព |
| ១២១ | ១៨២០០ | ការផលិតសារឡើងវិញ នូវសារឯកសារដែលបានថតចម្លងទុក |
| ១២២ | ២០១២០ | កម្មន្តសាល ជី និងសមាសធាតុនីត្រូហ្សែន |
| ១២៣ | ២០២៣០ | កម្មន្តសាល សាប៊ូដុំ ម្សៅសាប៊ូ សាប៊ូទឹក គ្រឿងសម្អាតនិងប៉ូលា គ្រឿងក្រអូប និងគ្រឿងសម្អាង |
| ១២៤ | ២០២៩១ | កម្មន្តសាល កាំជ្រួច |
| ១២៥ | ២០៣០០ | កម្មន្តសាល សរសៃសំយោគ |
| ១២៦ | ២១០០០ | កម្មន្តសាលឱសថសារជាតុគីមីសម្រាប់ព្យាបាលនិងផលិតផលឱសថធ្វើពីរុក្ខជាតិ |
| ១២៧ | ២២១១០ | កម្មន្តសាល សំបកកង់ និងពោះវៀនកង់និងការចាក់ពុម្ពឡើងវិញ និងការធ្វើជាថ្មីនៃកៅស៊ូកង់ |
| ១២៨ | ២២១៩០ | កម្មន្តសាល នៃផលិតផលកៅស៊ូដទៃទៀត |
| ១២៩ | ២២២១០ | កម្មន្តសាល គ្រឿងសំណង់ធ្វើពីប្លាស្ទិក |
| ១៣០ | ២៣១០០ | កម្មន្តសាល កញ្ចក់និងផលិតផលពីកញ្ចក់ |
| ១៣១ | ២៣៩១០ | កម្មន្តសាល ផលិតផលធន់កម្តៅ |
| ១៣២ | ២៣៩២១ | កម្មន្តសាល គ្បឿងប្រក់ដំបូល |
| ១៣៣ | ២៣៩២២ | កម្មន្តសាល ឥដ្ឋ |
| ១៣៤ | ២៣៩២៣ | កម្មន្តសាល កម្រាលក្រាលធ្វើពីដីឥដ្ឋដុត |
| ១៣៥ | ២៣៩២៩ | កម្មន្តសាល សម្ភារៈសំណង់ធ្វើពីដីឥដ្ឋដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៣៦ | ២៣៩៣០ | កម្មន្តសាល ផលិតផលពីព័រសឺឡែន និងសេរ៉ាមិកដទៃទៀត |
| ១៣៧ | ២៣៩៤២ | កម្មន្តសាល កំបោរ |
| ១៣៨ | ២៣៩៥០ | កម្មន្តសាល របស់របរប្រើប្រាស់ធ្វើពីកំបោរ ស៊ីម៉ងត៍និងប្លាស្ទ័រ |
| ១៣៩ | ២៣៩៦០ | ការកាត់ សូន និងកែច្នៃផលិតផលធ្វើអំពីថ្ម |
| ១៤០ | ២៤៣១០ | ការស្លចាក់ពុម្ពដែកនិងដែកថែប |
| ១៤១ | ២៤៣២០ | ការស្លចាក់ពុម្ពលោហធាតុមិនមែនដែក |
| ១៤២ | ២៥១១១ | កម្មន្តសាល ផលិតផលគ្រោង គ្រោងទ្វារ គ្រោងបង្អួច |
| ១៤៣ | ២៥១១២ | កម្មន្តសាល ស៊ុមរូបថត ស៊ុមកញ្ចក់ |
| ១៤៤ | ២៥១១៩ | កម្មន្តសាល ផលិតផលគ្រឿងគ្រោងពីលោហធាតុដទៃទៀត |
| ១៤៥ | ២៥៩១០ | ការដំ ការសង្កត់ ការវាយកាត់ និងការកិនលោហធាតុជារាង លោហកម្ម ម្សៅលោហធាតុ |
| ១៤៦ | ២៥៩២០ | ប្រព្រឹត្តិកម្ម និងការពាសលោហធាតុ ការក្រឡឹង |
| ១៤៧ | ២៥៩៣០ | កម្មន្តសាល គ្រឿងកាំបិតឧបករណ៍ដៃ និងគ្រឿងដែកប្រើប្រាស់ទូទៅ |
| ១៤៨ | ២៥៩៤០ | កម្មន្តសាល ធុងមានដៃយួរ កំប៉ុងធុងធំនិងកុងតឺន័រ ស្រដៀងគ្នាធ្វើពីលោហធាតុ |

| | | |
|---|---|---|
| ១៤៩ | ២៥៩៥០ | កម្មន្តសាល ផលិតផលខ្សែច្រវាក់ស៊ែរ និងវីសមួល-លើកលែងខ្សែកាបធ្វើពីលោហធាតុ |
| ១៥០ | ២៥៩៩១ | កម្មន្តសាល ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ |
| ១៥១ | ២៥៩៩៩ | កម្មន្តសាល ផលិតផលពីលោហធាតុកែច្នៃដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៥២ | ២៧៥៣០ | កម្មន្តសាល បរិក្ខារប្រើប្រាស់សម្រាប់ចម្អិនអាហារ និងកម្តៅមិនប្រើអគ្គិសនី សម្រាប់ប្រើប្រាស់ក្នុងផ្ទះ |
| ១៥៣ | ២៩២០១ | កម្មន្តសាលរ៉ឺម៉កសណ្តោង |
| ១៥៤ | ២៩២០៩ | ការផលិតតួយានយន្ត កម្មន្តសាលរ៉ឺម៉កសណ្តោងនិងពាក់កណ្តាលសណ្តោង ដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៥៥ | ៣០១១២ | ការផលិតទូកនេសាទ |
| ១៥៦ | ៣០១២០ | ការផលិតទូកកម្សាន្ត និងទូកកីឡា |
| ១៥៧ | ៣០៩២២ | កម្មន្តសាលរទេះជនពិការ |
| ១៥៨ | ៣០៩២៩ | កម្មន្តសាលទោចក្រយាន និងរទេះជនពិការដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៥៩ | ៣០៩៩០ | កម្មន្តសាលបរិក្ខារដឹកជញ្ជូនដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៦០ | ៣១០០១ | កម្មន្តសាលគ្រឿងសង្ហារិមធ្វើពីឈើ |
| ១៦១ | ៣១០០២ | កម្មន្តសាលគ្រឿងសង្ហារិមធ្វើពីបេតុង |
| ១៦២ | ៣១០០៣ | កម្មន្តសាលគ្រឿងសង្ហារិមធ្វើពីដែក |
| ១៦៣ | ៣១០០៤ | កម្មន្តសាលគ្រឿងសង្ហារិមសាឡុង |
| ១៦៤ | ៣១០០៩ | កម្មន្តសាលគ្រឿងសង្ហារិមដទៃទៀតទៀតដែលពុំបានរាប់បញ្ចូល |
| ១៦៥ | ៣២១១១ | កម្មន្តសាលគេនកណ្ឌ និងរបស់របរពាក់ព័ន្ធដែលធ្វើពីមាស |
| ១៦៦ | ៣២១១២ | កម្មន្តសាលគេនកណ្ឌ និងរបស់របរពាក់ព័ន្ធដែលធ្វើពីប្រាក់ |
| ១៦៧ | ៣២១១៣ | កម្មន្តសាលគេនកណ្ឌ និងរបស់របរពាក់ព័ន្ធដែលធ្វើពីថ្ម |
| ១៦៨ | ៣២១១៩ | កម្មន្តសាលគេនកណ្ឌដទៃទៀត និងរបស់របរពាក់ព័ន្ធដែលធ្វើពីវត្ថុធាតុមានតម្លៃ និងពាក់កណ្តាលមានតម្លៃដែលពុំបានរាប់បញ្ចូល |
| ១៦៩ | ៣២១២០ | កម្មន្តសាលគ្រឿងអលង្ការកាឡៃនិងអលង្ការស្រដៀងគ្នា |
| ១៧០ | ៣២២០១ | កម្មន្តសាលឧបករណ៍តន្ត្រីប្រពៃណី |
| ១៧១ | ៣២២០៩ | កម្មន្តសាលឧបករណ៍តន្ត្រីដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៧២ | ៣២៣០០ | កម្មន្តសាលសម្ភារៈកីឡា |
| ១៧៣ | ៣២៤០០ | កម្មន្តសាលហ្គេមនិងប្រដាប់ប្រដាក្មេងលេង |
| ១៧៤ | ៣២៥០០ | កម្មន្តសាលឧបករណ៍ និងគ្រឿងផ្គត់ផ្គង់សម្រាប់វេជ្ជសាស្ត្រនិងទន្តសាស្ត្រ |

**៤. សហគមន៍កសិកម្ម**

| | | |
|---|---|---|
| ១ | ០១១១១ | ការដាំដុះពោត |
| ២ | ០១១១២ | ការដាំដុះសណ្តែកបន្លែ សណ្តែកបារាំង សណ្តែកកួរ។ល។ |

| | | |
|---|---|---|
| ៣ | ០១១១៣ | ការដាំដុះសណ្តែកប្រេង សណ្តែកសៀង សណ្តែកដី ល្ង ផ្កាឈូករ័ត្ន ពោតសម្រាប់ចំណីសត្វ |
| ៤ | ០១១១៩ | ការដាំដុះដំណាំធញ្ញជាតិ ដទៃទៀត ដែលពុំបានរាប់បញ្ចូល |
| ៥ | ០១១២០ | ការដាំដុះស្រូវ |
| ៦ | ០១១៣១ | ការដាំដុះបន្លែយកដើមនិងស្លឹក ទំពាំងបារាំង ស្ពៃក្តោប ស្ពៃចង្កឹះ សាលាដ។ល។ |
| ៧ | ០១១៣២ | ការដាំដុះបន្លែយកផ្លែ ត្រសក់ ប៉េងប៉ោះ។ល។ |
| ៨ | ០១១៣៣ | ការដាំដុះដំណាំអម្បូរត្រសក់ផ្អែម ឪឡឹក ត្រសក់ស្រូវ។ល។ |
| ៩ | ០១១៣៤ | ការដាំដុះផ្សិត |
| ១០ | ០១១៣៥ | ការដាំដុះបន្លែគ្រាប់ |
| ១១ | ០១១៣៦ | ការដាំដុះបន្លែគ្រាប់ផ្សេងទៀត |
| ១២ | ០១១៣៧ | ការដាំដុះដំណាំយកឫស ឬមើម ដំឡូងមី ដំឡូងផ្អែម(ដំឡូងជ្វា ដំឡូងគ។ល។) ការ៉ុត ខ្ទឹមស ក្តួច ឬដំឡូងឈើផ្សេងទៀត។ល។ |
| ១៣ | ០១១៤០ | ការដាំដុះអំពៅ |
| ១៤ | ០១១៥០ | ការដាំដុះថ្នាំជក់ |
| ១៥ | ០១១៦០ | ការដាំដុះកប្បាស និងដំណាំសរសៃដទៃទៀត |
| ១៦ | ០១១៩១ | ការដាំដុះផ្កា រាប់ទាំងផលិតកម្មផ្កាដែលកាត់ពីដើម ក្រពុំផ្កា និងគ្រាប់ផ្កា |
| ១៧ | ០១១៩២ | ការដាំដុះសាគូ |
| ១៨ | ០១១៩៩ | ការដាំដុះដំណាំអាយុកាលខ្លីដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ១៩ | ០១២១០ | ការដាំដុះទំពាំងបាយជូរ |
| ២០ | ០១២២១ | ការដាំដុះចេក |
| ២១ | ០១២២២ | ការដាំដុះស្វាយ |
| ២២ | ០១២២៣ | ការដាំដុះទុរេន |
| ២៣ | ០១២២៤ | ការដាំដុះសាវម៉ាវ |
| ២៤ | ០១២២៥ | ការដាំដុះមៀន |
| ២៥ | ០១២២៦ | ការដាំដុះល្ហុង |
| ២៦ | ០១២២៧ | ការដាំដុះម្នាស់ |
| ២៧ | ០១២២៨ | ការដាំដុះស្រកានាគ |
| ២៨ | ០១២២៩ | ការដាំដុះផ្លែឈើតំបន់ត្រូពិច និងអនុតំបន់ត្រូពិចដទៃទៀត ដែលពុំបានរាប់បញ្ចូល (ល្មុត លាំងសាតគ្រប់ប្រភេទ ចម្ប៉ាដាក់ ខ្នុរ មង្ឃុត រកាំ សិរមាន់ ផ្លែប័រ។ល។) |
| ២៩ | ០១២៣១ | ការដាំដុះក្រូចថ្លុង |
| ៣០ | ០១២៣២ | ការដាំដុះក្រូចឆ្មារ |
| ៣១ | ០១២៣៣ | ការដាំដុះក្រូចឃ្វិច និងក្រូចពោធិ៍សាត់ |
| ៣២ | ០១២៣៩ | ការដាំដុះដំណាំក្រូចដទៃទៀត ដែលពុំបានរាប់បញ្ចូល |
| ៣៣ | ០១២៤១ | ការដាំដុះត្របែក |

L202404240281TD4109

| | | |
|---|---|---|
| ៣៤ | ០១២៤៩ | ការដាំដុះដំណាំហូបផ្លែ និងមានគ្រាប់ដទៃទៀត ដែលពុំបានរាប់បញ្ចូល |
| ៣៥ | ០១២៥១ | ការដាំដុះដំណាំហូបផ្លែ ស្ត្របឺរី ប្លូបឺរី គីវី និងពពួកដំណាំហូបផ្លែដទៃទៀត |
| ៣៦ | ០១២៥២ | ការដាំដុះដំណាំហូបគ្រាប់ |
| ៣៧ | ០១២៥៣ | ការដាំដុះស្វាយចន្ទី និងគ្រាប់ផ្លែឈើដែលអាចហូបបានដទៃទៀត |
| ៣៨ | ០១២៥៩ | ការដាំដុះដំណាំហូបផ្លែ ប្រភេទដើមឈើនិងចុល្លព្រឹក្សដទៃទៀត ការដាំដុះសណ្តែកឡូកាស។ល។ |
| ៣៩ | ០១២៦១ | ការដាំដុះដូងប្រេង |
| ៤០ | ០១២៦២ | ការដាំដុះដូង |
| ៤១ | ០១២៧១ | ការដាំដុះកាហ្វេ |
| ៤២ | ០១២៧២ | ការដាំដុះតែ |
| ៤៣ | ០១២៧៣ | ការដាំដុះកាកាវ |
| ៤៤ | ០១២៧៩ | ការដាំដុះដំណាំសម្រាប់ផលិតភេសជ្ជៈដទៃទៀត ដែលពុំបានរាប់បញ្ចូល |
| ៤៥ | ០១២៨១ | ការដាំដុះម្រេច |
| ៤៦ | ០១២៨២ | ការដាំដុះម្ទេស |
| ៤៧ | ០១២៨៣ | ការដាំដុះចន្ទន៍ក្រស្នា |
| ៤៨ | ០១២៨៤ | ការដាំដុះខ្ញី |
| ៤៩ | ០១២៨៥ | ការដាំដុះរុក្ខជាតិប្រើជាចម្បងសម្រាប់ធ្វើទឹកអប់ ឱសថ ឬថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ផ្សិត ការដាំដុះស្លឹកគ្រៃ ស្លឹកតើយ។ល។ |
| ៥០ | ០១២៨៩ | ការដាំដុះរុក្ខជាតិគ្រឿងទេស និងរុក្ខជាតិយកក្លិនដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៥១ | ០១២៩២ | ការដាំដុះកៅស៊ូ-ចម្ការតូច |
| ៥២ | ០១២៩៣ | ការដាំដុះដើមឈើដើម្បីដកយករុក្ខរស |
| ៥៣ | ០១២៩៤ | ការដាំដុះដើមត្នោត |
| ៥៤ | ០១២៩៥ | ការដាំដុះដើមស្លា |
| ៥៥ | ០១២៩៦ | ការដាំដុះដើមរ៉ូហ្សេល |
| ៥៦ | ០១២៩៩ | ការដាំដុះដំណាំអាយុកាលវែងដទៃទៀតដែលពុំបានរាប់បញ្ចូល ក).ការដាំដុះដើមស្រល់សាប៉ាំង (ដើមគ្រិស្មាស់) ខ).ការដាំដុះរុក្ខជាតុដើមនៃប្រភេទស្រល់នេះ ប្រើជាចម្បងសម្រាប់ដាំដុះ |
| ៥៧ | ០១៣០១ | ការបណ្តុះរុក្ខជាតិដោយគ្រាប់ រុក្ខជាតិសម្រាប់តុបតែង និងស្មៅបន្សាំ |
| ៥៨ | ០១៣០២ | ការបណ្តុះរុក្ខជាតិដោយវិធីសាស្ត្រដទៃទៀត ការដាំដុះរុក្ខជាតិរស់ សម្រាប់យកគល់ មើមនិងឫស មែកនិងស្លឹក មេផ្សិត |
| ៥៩ | ០១៤១១ | ការចិញ្ចឹម ការបង្កាត់ពូជនិងផលិតកម្មគោនិងក្របី |
| ៦០ | ០១៤១២ | ផលិតកម្មទឹកដោះគោស្រស់ពីគោឬក្របី |
| ៦១ | ០១៤១៣ | ការចិញ្ចឹមយកមេជីវិតគោឬក្របី |
| ៦២ | ០១៤២០ | ការចិញ្ចឹមនិងការបង្កាត់ពូជសេះលា សេះទេសឬលាទេស |
| ៦៣ | ០១៤៤១ | ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មចៀមនិងពពែ |

L202404240281TD4109

| | | |
|---|---|---|
| ៦៤ | ០១៤៤២ | ការផលិតទឹកដោះស្រស់របស់សត្វចៀមនិងពពែ |
| ៦៥ | ០១៤៥០ | ការចិញ្ចឹម ការបង្កាត់ពូជនិងផលិតកម្មជ្រូក |
| ៦៦ | ០១៤៦១ | ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មកូនមាន់និងមាន់សម្រាប់យកសាច់ |
| ៦៧ | ០១៤៦២ | ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មទា |
| ៦៨ | ០១៤៦៣ | ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មក្ងាន |
| ៦៩ | ០១៤៦៤ | ការចិញ្ចឹម ការបង្កាត់ពូជបសុបក្សីដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៧០ | ០១៤៦៥ | ផលិតកម្មស៊ុតមាន់ |
| ៧១ | ០១៤៦៦ | ផលិតកម្មស៊ុតទា |
| ៧២ | ០១៤៦៩ | ផលិតកម្មស៊ុតបសុបក្សីដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៧៣ | ០១៤៩១ | ដំណើរការកន្លែងចិញ្ចឹមសិប្បីសត្វ ដូចជា ខ្យង។ល។ |
| ៧៤ | ០១៤៩២ | ការចិញ្ចឹមដង្កូវនាង និងផលិតកម្មសម្បុកដង្កូវនាង |
| ៧៥ | ០១៤៩៣ | ការចិញ្ចឹមឃ្មុំ និងផលិតកម្មទឹកឃ្មុំនិងក្រមួនឃ្មុំ |
| ៧៦ | ០១៤៩៩ | ការចិញ្ចឹមសត្វដទៃទៀតរាប់ទាំងសត្វប្លែកៗ និងសត្វមានជីវិតដទៃទៀត បក្សីអ៊ីមូល សត្វល្អិត ទន្សាយ និងសត្វដែលមានរោមដទៃទៀត |
| ៧៧ | ០១៦១០ | សកម្មភាពកសិកម្មតាមការបង់ថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា ក).ការរៀបចំទីកសិកម្ម ការប្រមូលផល ការគ្រប់គ្រងកត្តាចង្រៃបំផ្លាញដំណាំ (រួមទាំងទន្សាយ)ដែលពាក់ព័ន្ធនឹងកសិកម្ម។ល។ ខ).ការដំណើរការឧបករណ៍ស្រោចស្រព ដែលពាក់ព័ន្ធនឹងកសិកម្ម គ).ការថែទាំដីដើម្បីឱ្យនៅមានសភាពល្អ សម្រាប់ការងារកសិកម្ម |
| ៧៨ | ០១៦២០ | សកម្មភាពគាំទ្រដល់ផលិតកម្មសត្វ តាមការបង់ថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា ក). សកម្មភាពដើម្បីជំរុញឱ្យមានការបង្កាត់/ផ្សាំ ការលូតលាស់ទទួលទិន្នន័យពីសត្វ ខ). សកម្មភាពទាក់ទងទៅនឹងការបង្កាត់ពូជបែបសិប្បនិម្មិត គ).សកម្មភាពផ្តល់ចំណី ក្នុងកន្លែងចិញ្ចឹមសត្វដោយគ្មានការថែរក្សាសុខភាព ឃ).សកម្មភាពសាកល្បងមកលើហ្វូងសត្វ សកម្មភាពកៀងហ្វូងគោ សកម្មភាពចិញ្ចឹមគោនិងសកម្មភាពគ្រៀវ បសុបក្សី |
| ៧៩ | ០១៦៣០ | ការរៀបចំផលដំណាំសម្រាប់ទីផ្សារបន្ទាប់ពីប្រមូលផលរួច ការសម្អាត ការកាត់តម្រឹម ការបែងចែកគុណភាព ការសម្លាប់មេរោគ ការយកគ្រាប់កប្បាសចេញ |
| ៨០ | ០១៦៤០ | ការកែច្នៃគ្រាប់ពូជសម្រាប់បណ្តុះ |
| ៨១ | ០២១០០ | វនវប្បកម្ម រាប់បញ្ចូលទាំងការដាំដុះដើមឈើ ក).ការដាំដុះដើមឈើបន្ថែមសម្រាប់ជួសឱ្យមានព្រៃក្រាស់ឡើងវិញ ខ).ការដាំដុះព្រៃឈើ គ).ការដាំដុះដើមឈើតាមផ្លូវធំៗ តាមឆ្នេរសមុទ្រ ឬនៅទីវាល ឃ).ការដាំដុះដើមឈើសម្រាប់ផលិតក្រដាស និងអុសដុត ង).ការប្រមូលដើមរុក្ខជាតិព្រៃ ច).ការបណ្តុះកូនឈើសម្រាប់ដាំព្រៃឈើ |
| ៨២ | ០២៣០០ | ការប្រមូលអនុផលព្រៃឈើ ក).ការប្រមូលផ្តៅ ឬឫស្សី ខ).ការប្រមូលសម្បុកបក្សី គ).ការប្រមូលសាគូព្រៃ ឃ).ការប្រមូលរុក្ខសេពីរុក្ខជាតិ ង).ខ្សែឫសរសៃ ផ្លែឈើ ស្លឹកឈើ និងប្រេងពីដើមឈើក្នុងព្រៃ ច).ក្រមួនឃ្មុំ និងទឹកឃ្មុំ |

| | | |
|---|---|---|
| ៨៣ | ០៣១១១ | ការចាប់ត្រីសមុទ្រ ការចាប់ត្រីបាឡែន |
| ៨៤ | ០៣១១២ | ការចាប់បង្គា |
| ៨៥ | ០៣១១៣ | ការចាប់ក្តាមសមុទ្រ |
| ៨៦ | ០៣១១៤ | ការចាប់ត្រីមឹក |
| ៨៧ | ០៣១១៥ | ការប្រមូលសម្បកសិប្បីសត្វសមុទ្រ និងគជ់ខ្យង |
| ៨៨ | ០៣១១៩ | ការនេសាទត្រីសមុទ្រដទៃទៀតដែលពុំបានរាប់បញ្ចូល |
| ៨៩ | ០៣១២១ | ការចាប់ត្រីទឹកសាប |
| ៩០ | ០៣១២២ | ការចាប់បង្កងទឹកសាប បង្គា និងសត្វអម្បូរសម្បករឹងដទៃទៀត |
| ៩១ | ០៣១២៩ | ការនេសាទត្រីទឹកសាបដទៃទៀត ដែលពុំបានរាប់បញ្ចូល |
| ៩២ | ០៣២១១ | ការចិញ្ចឹមត្រីក្នុងទឹកសមុទ្រ ការចិញ្ចឹមត្រីទឹកប្រៃសម្រាប់តាំងលម្អ |
| ៩៣ | ០៣២១២ | ផលិតកម្មកូនសត្វពពួកគ្រំ-អ័យស្ទ័រ គ្រំចំពុះទា កូនបង្កងកូនបង្គា កូនត្រី |
| ៩៤ | ០៣២១៣ | ការដាំដុះសារាយសមុទ្រនិងរុក្ខជាតិផ្សេងទៀតដែលអាចញ៉ាំបាន |
| ៩៥ | ០៣២១៤ | ការចិញ្ចឹមសត្វអម្បូរសម្បករឹង ពពួកគ្រំនិងសិប្បីសត្វផ្សេងទៀត និងវារីសត្វសមុទ្រដទៃទៀត |
| ៩៦ | ០៣២១៥ | សកម្មភាពវារីវប្បកម្មនៅក្នុងទឹកភ្លាវ |
| ៩៧ | ០៣២១៩ | វារីវប្បកម្មក្នុងទឹកប្រៃដទៃទៀត ដែលពុំបានរាប់បញ្ចូល |
| ៩៨ | ០៣២២១ | ការចិញ្ចឹមត្រីនៅក្នុងទឹកសាប |
| ៩៩ | ០៣២២២ | ការចិញ្ចឹមបង្គា បង្កងទឹកសាប នៅក្នុងទឹកសាប |
| ១០០ | ០៣២២៣ | ការចិញ្ចឹមក្រពើ និងក្រពា |
| ១០១ | ០៣២២៤ | វារីវប្បកម្មក្នុងទឹកសាបសម្រាប់តាំងលម្អ |
| ១០២ | ០៣២២៥ | ការចិញ្ចឹមកង្កែប |
| ១០៣ | ០៣២២៩ | វារីវប្បកម្មក្នុងទឹកសាបដទៃទៀត ដែលពុំបានរាប់បញ្ចូល |